MULTICULTURAL HIV AND HEPATITIS SERVICE



# HIV ➢ ផលវិបាកនៃមេរោគ ហេច្ចអាយវី និងជំងឺអេដស៍

3.1 តើមេរោគ HIV និង ជំងឺ AIDS ខុសគ្នាដូចម្ដេច?

3.2 តើមេរោគ HIV ឆ្លងតាមរបៀបណា?

3.3 តើមេរោគ HIV ប៉ះពាល់ប្រពន្ធ័ការពារប្រឆាំងនឹងមេរោគរបស់យើងរបៀបណា?

## 3.1 តើមេរោគ ហេច្ចអាយវី និងជំងឺអេដស៍ខុសគ្នាដូចម្ដេច?

ជារឿយៗគេច្រើនប្រើពាក្យ HIV និង AIDS ចូលគ្នាហើយយល់ថាពាក្យទាំងនេះមានន័យតែមួយ ។ ប៉ុន្តែ HIV និង AIDSគឺមានន័យពីរខុសគ្នា ។ HIV គឺមកពីពាក្យមេរោគធ្វើឱ្យភាពសាំុនឹងជំងឺក្នុងខ្លួនរបស់មនុស្សទន់ខ្សោយ ។ HIV គឺជាមេរោគវីរើស (Virus) ដែលអាចបណ្ដាលឱ្យកើតជំងឺ AIDS ។
បើសិនជាអ្នកបានឆ្លងមេរោគ HIV (infected with HIV) នោះអ្នកមានមេរោគ HIV វិជ្ជមានក្នុងខ្លួន ។ នេះមានន័យថា មេរោគ HIV បានចូលក្នុងប្រពន្ធ័ឈាមរបស់ អ្នក ។ នៅពេលនោះគ្មានវិធីព្យាបាលទេ ហើយមេរោគនឹងនៅក្នុងឈាមអ្នកជារៀងរហូត ។

យ៉ាងណាមិញ គឺជាការសំខាន់ដែលអ្នកត្រូវចងចាំថាមានមនុស្សជាច្រើនដែលមានមេរោគ HIV វិជ្ជមានតែមានសុខភាពល្អធម្មតា ។ AIDS មកពីពាក្យដែលមានន័យថា ប្រពន្ធ័ប្រឆាំងការពារនឹងមេរោគ ឬភាពសាំុនឹងជំងឺក្នុងខ្លួនចុះខ្សោយ (Acquired Immune Deficiency Syndrome) រោគសញ្ញាជំងឺ AIDS មិនមែនជាជំងឺមួយមុខទេ តែវាជាជំងឺច្រើនមុខដែលផ្ដុំឡើងជាក្រុម ពីព្រោះ ខ្លួនរបស់មនុស្ស ដែលមាន ជំងឺអេដស៍ពុំអាចទប់ទល់ប្រឆាំងនឹងមេរោគបានដូច សព្វដង ។ នៅពេលដែលមេរោគHIV បានជ្រាបចូលក្នុងឈាមប្រពន្ធ័ការពារប្រឆាំងនឹងមេរោគ (immune system) ដែលសំរាប់ទប់ទល់ប្រឆាំងនឹងជំងឺឆ្លង និងមេរោគនានារបស់មនុស្សនោះត្រូវខូចខាត ។ ជាច្រើនឆ្នាំក្រោយមក ប្រពន្ធ័ការពារ ជំងឺអាចខូចទៅៗ ។ បើអ្នកមានមេរោគ HIV ហើយត្រូវបានគេពិនិត្យ ឬរកឃើញរោគវិនិច្ឆ័យ (Diagnosed) មានជំងឺម្យ៉ាង ឬច្រើននោះ ទើបគេសន្និដ្ឋានថា អ្នកមានជំងឺ AIDS ។

មេរោគ HIV គឺជាមេរោគដែលឆ្លងពីមនុស្សម្នាក់ទៅម្នាក់ទៀតបានបើសិនជាមេរោគនោះចូលទៅក្នុងប្រពន្ធ័ឈាម ។ AIDS គឺជាជំងឺ ដែលវិវឌ្ឍន៍ក្នុងអំឡុងពេលយូរអង្វែងដោយសារការឆ្លងនូវមេរោគ HIV ។ អ្នកមិនអាចឆ្លងជំងឺ AIDS ឬក៏ចម្លងជំងឺAIDS ពីមនុស្សម្នាក់ទៅមនុស្សម្នាក់បានទេ ប៉ុន្តែមេរោគអាចចម្លងបាន ។ បើសិនជាអ្នកត្រូវបានគេប្រាប់ថាអ្នកមានមេរោគ HIV វិជ្ជមាន នោះមានន័យថាអ្នកមានមេរោគ HIV ។ វាគឺមិនមានន័យថា អ្នកមានជំងឺ AIDSនោះទេ ។ គេពុំទាន់មានវិធីព្យាបាលមេរោគ HIVទេប៉ុន្តែគេអាច ជួយពន្យារពេល ជាច្រើនឆ្នាំ ទំរាំតែកើត ជំងឺAIDS ។

## 3.2 តើមេរោគ ហេច អាយ វីឆ្លងតាម របៀបណា?

មេរោគ HIV ត្រូវបានគេរកឃើញនៅក្នុងវត្ថុរាវក្នុងខ្លួន ដូចជា ឈាមទឹកកាមបុរស (Semen) ទឹករំអិលក្នុងប្រដាប់បន្តពូជស្ត្រី (Virginal Fluids) ហើយនិងទឹកដោះម្ដាយ ។ ការឆ្លងនៃមេរោគ HIV អាចកើតមានឡើងនៅពេលដែលវត្ថុរាវទាំងនេះរបស់អ្នកមានមេរោគ HIV ចូលទៅក្នុងប្រពន្ធ័ឈាមនៃមនុស្សម្នាក់ទៀត ។

មេរោគ HIV អាចឆ្លងតាមរបៀបខាងក្រោមនេះ :

**ការរួមភេទ**

ដោយសារតែមេរោគ HIV មាននៅក្នុងទឹកកាមបុរស និងទឹករំអិលស្ត្រីវាអាចឆ្លងបាន តាមការរួមដំណេក (Sexual intercourse) ដោយសារមានការដាច់ដ៏តូចៗហើយនិងរលាត់នៃសន្ទះស្តើងរបស់ស្ត្រី ឬក៏ស្បែកសន្ទះស្តើងនៃលិង្គបុរសរន្ធគូថឬយោនី ។

ដើម្បីជៀសវាងការចម្លងមេរោគ HIV សូមប្រតិបត្តិការរួមដំណេកដោយប្រុងប្រយត្ន័ដូចជា:

1. ប្រើស្រោមអនាម័យថ្មី (condom) និងប្រដាប់រំអិលដែលធ្វើពីជាតិទឹក (ឧ. Ky Jelley or Wetstuff) សំរាប់គូថ ឬយោនីក្នុងពេលរួមដំណេក ។
2. ជៀសវាងការរួមដំណេកផ្ទាល់ ដោយដាក់ចូលតាមផ្លូវកាម (Penetration sex) (ដែលលិង្គរបស់បុរសចូលទៅក្នុងរន្ធគូថឬយោនី)
3. ប្រើស្រោមអនាម័យឬក៏សន្ទះទប់ (Dams) នៅពេលដែលរួមដំណេកដោយមាត់ ។ ការរួមដំណេកដោយមាត់ គឺចាត់ទុកថាមានការឆ្លងយ៉ាងតិចតួចណាស់ ប៉ុន្តែការឆ្លងអាចកើតមានឡើងបើសិនមានដាច់កាត់ ដំបៅនៅក្នុងមាត់ ឬក៏នៅលើប្រដាប់បន្តពូជ (Genitals) ។

**របៀបប្រើស្រោមអនាម័យ (ស្រោមលិង្គ)**

1. ចូរហែកកញ្ចប់ស្រោមលិង្គ ដោយប្រុងប្រយ័ត្ន ដើម្បីកុំឱ្យស្រោមលិង្គរហែក ។ (ទាញស្បែកនៅ មុខលិង្គមកក្រោយ (បើចាំបាច់) ។



2. សង្កត់ចុងស្រោមលិង្គដោយប្រើម្រាមដៃ និងម្រាមដៃដើម្បីឱ្យខ្យល់ចេញពីចុងស្រោមលិង្គរួចរុញពន្លាគ្របទៅលើលិង្គ ។



3. ពេលដែលស្រោមលិង្គពាក់លើលិង្គហើយ អ្នកគួរប្រើទឹករំអិល (water-based lubricant) ។



4. ចូរកាន់ទ្រស្រោមលិង្គឱ្យជាប់នៅពេលដកលិង្គចេញមកវិញ ដើម្បីការពារកុំឱ្យទឹកកាមចូលក្នុងយោនីនាំឱ្យមានផ្ទៃពោះ ។



5. ចូរចោលស្រោមលិង្គទៅក្នុងធុងសំរាម ។



**ដាច់ខាតកុំប្រើស្រោមអនាម័យដែលគេប្រើហើយ ។**

**ការប្រើសឺរាំង និងឧបករណ៍ចាក់ថ្នាំរួមគ្នា ចោះរន្ធលើខ្លួនឬសាក់**

ចំនួនឈាមដ៏តិចតួចដែលផ្ទុកដោយមេរោគ អាចជាប់ទៅនឹងម្ជុល និងស៊ីរាំង ។ ឈាមនេះអាចចូលទៅក្នុងប្រពន្ធ័ឈាម នៃមនុស្សម្នាក់ទៀត

ដែលប្រើម្ជុល ឬស៊ីរាំងតាមក្រោយ ។
ដើម្បីជៀសវាងនូវការឆ្លងមេរោគ HIV ចូរកុំប្រើម្ជុលនិងសឺរាំងរួមគ្នាឬប្តូរឧបករណ៍ ដទៃទៀតសំរាប់ចាក់ថ្នាំ ។ បើសិនជាអ្នកត្រូវការសាក់ចោះរន្ធនៅលើខ្លួន សូមទៅកន្លែងមានសញ្ញាប័ត្រ (Licensed Studio) ត្រឹមត្រូវដែលកន្លែងនោះម្ជុល ហើយនិងឧបករណ៍ដទៃទៀត ត្រូវបានគេបោះចោលបន្ទាប់ពីប្រើរួច ឬក៏រំងាប់មេរោគត្រឹមត្រូវ ។ ការប្រតិបត្តិទាំងនេះនឹងជួយការពារនូវមេរោគធ្ងន់ៗដ៏ទៃទៀត ហើយនិងការឆ្លងដូចជាជំងឺរលាកថ្លើមប្រភេទ B និង C ផងដែរ ។

**ម្តាយចម្លងទៅកូន**

ស្ត្រីដែលមានផ្ទុកមេរោគ HIV វិជ្ជមាន
(HIV Positive) អាចចម្លងមេរោគ HIV ទៅកូនរបស់ខ្លួនឯងនៅក្នុងកំឡុងពេលមានផ្ទៃពោះ និងពេលឆ្លងទន្លេ ។ ដោយការថែរក្សានិងការព្យាបាលជិតដល់ ស្ត្រីដែលមាន មេរោគ HIV វិជ្ជមានជាច្រើនអាចមានកូនដោយគ្មានរោគឡើយ ។ បើសិនជាអ្នកមានផ្ទៃពោះ ឬក៏មានគំរោងការណ៍ចង់បានកូន វាជាការសំខាន់ដែលអ្នកពិភាក្សាជាមួយវេជ្ជបណ្ឌិតឱ្យបានទាន់វេលា ។ នៅក្នុងប្រទេសអូស្ត្រាលីមានកិច្ចបំរើណែនាំដល់ស្ត្រី ណាដែលមានមេរោគ HIV មិនឱ្យបំបៅកូនដោយទឹកដោះខ្លួនផ្ទាល់ព្រោះមេរោគ HIV មាននៅក្នុងទឹកដោះ ។ មានផ្តល់ជូននូវពត៌មាននិងវិធីផ្សេងៗទៀតដែរអំពីរបៀបបំបៅកូនដែលមានប្រសិទ្ធិភាព និងវិធីផ្សេងទៀតពីរបៀបចញ្ចឹមទារក ។

**ការបញ្ចូលឈាម ឬការផលិតធ្វើពីឈាម**

មុនពេលយើងដឹងពីមេរោគ HIV ការផ្តល់ឈាមអាចមានគ្រោះថ្នាក់បំផុត ។ យ៉ាងណាមិញចាប់តាំងពីឆ្នាំ ១៩៨៥ ឈាមទាំងអស់ ត្រូវបានគេ ពិនិត្យមើលមេរោគ HIV ។ ការបញ្ចូលឈាមគឺនៅតែមានគ្រោះថ្នាក់ខ្លាំងនៅប្រទេសដ៏ទៃទៀត ។ មនុស្សណាដែលមានមេរោគ HIV វិជ្ជមាន ពុំអាចធ្វើអំណោយឈាមបានឡើយ ។ មេរោគ HIV ក៏ត្រូវបានគេរកឃើញផងដែរនៅក្នុងវត្ថុរាវនៃសរីរាង្គដូចជាកំអួត ( ក្អួត) ស្លេស និងលាមក ។ វត្ថុរាវនៃសរីរាង្គទាំងនេះមិនចាត់ទុកជាគ្រោះថ្នាក់ នៃការចម្លងមេរោគ HIV ទេ ពីព្រោះចំនួននៃកំរិតឈាម និងមេរោគ HIV នៅក្នុងនោះមានតិចតួចណាស់ ។ យ៉ាងណាមិញ សំរាប់អនាម័យទូទៅមនុស្សគ្រប់រូបគួរតែលាងសំអាតដៃរបស់ខ្លួនបន្ទាប់ពីប៉ះវត្ថុរាវនៃសរីរាង្គ ។

**មេរោគ HIV មិនអាចឆ្លងតាមរបៀបៈ**

- ក្អក
- កណ្តាស់
- ស្តោះទឹកមាត់
- ថើប
- យំ
- ប្រើស្លាបព្រា និងចានឆ្នាំងរួម
- កំរាលពូក
- បង្គន់ បន្ទប់ទឹក ឬ

- ការប៉ះពាល់គ្នាធម្មតា

សត្វល្អិតដូចជាមូស មិនអាចចម្លងមេរោគ HIV ទេ ។ មេរោគ HIV គឺជាមេរោគនៃឈាមនេះមានន័យថា វាអាចចម្លងបានបើសិនជាឈាមមានមេរោគនៃមនុស្សម្នាក់ចូលទៅក្នុងប្រព័ន្ធឈាម មនុស្សម្នាក់ទៀត ។ មេរោគ HIV អាចឆ្លងបានតាម ការរួមដំណេកមិនប្រយត្ន័រវាងបុរសនិងស្ត្រី បុរសនិងបុរស ស្ត្រីនិងស្ត្រី តាមការប្រើម្ជុលរួមគ្នា ឬក៏សីរាំងជាមួយមនុស្សមានមេរោគនេះ ឬក៏ពីម្តាយទៅកូន ។

### 3.3 តើមេរោគ HIV ប៉ះពាល់ ប្រពន្ធ័ការពារប្រឆាំង មេរោគរបស់យើងរបៀបណា?

មេរោគវីរ៉ុស (Virus) គឺអង្គធាតុមានជីវិតយ៉ាងតូចៗដែលអាចចូលទៅក្នុងខ្លួន បណ្តាលឱ្យកើតជំងឺ ។ វាចម្លង ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរបៀបខុសៗគ្នា ហើយបណ្តាលឱ្យកើតជំងឺផ្សេងៗខុសគ្នា ។ ឧទាហរណ៍ ដូចជា ជំងឺផ្តាសាយ កញ្រ្ជិល ស្វាយបែកហើយនិងជំងឺស្វិតដៃជើងនេះគឺបណ្តាលមកពីវីរ៉ុស ។

ជំងឺផ្តាសាយនិងកញ្រ្ជិលឆ្លងតាមខ្យល់ ជំងឺស្វាយបែកឆ្លងតាមការប៉ះគ្នា និងជំងឺស្វិតដៃជើងមកពីការញ៉ាំទឹកមិនស្អាត ។ មេរោគ HIV ឆ្លងបានលុះត្រាតែមេរោគបានជ្រាបចូលទៅក្នុងប្រពន្ធ័ឈាម ។ បន្ទាប់មកមេរោគបណ្តាលឱ្យកើតជំងឺនៃប្រពន្ធ័ភាពស៊ាំក្នុងខ្លួន ។

ភាពស៊ាំនៅក្នុងខ្លួនអាចជួយការពារអ្នកកើតពីការឆ្លងជំងឺ និងមេរោគនានា ។ ភាពស៊ាំទាំងនេះគឺបង្កើតឡើងដោយកោសិកាផ្សេងៗដែលធ្វើការ រួមគ្នាដើម្បីចំណាំ និងបំផ្លាញមេរោគនៃវីរ៉ុសបាក់តេរី និងមេរោគផ្សេងទៀត ។

អ្នកនឹងត្រូវបានគេប្រាប់ថា អ្នកមានមេរោគ HIV វិជ្ជមាន បន្ទាប់ពីបានធ្វើការពិនិត្យឈាម ហៅថាតេស្តរកអង្គបដិបក្ខដែលប្រឆាំង និងមេរោគ HIV (HIV Anti-body Test) ។ តេស្តទាំងនេះគឺរកមើលជាតិប្រូតេអីនម្យ៉ាងនៅក្នុងឈាមហៅថាអង្គបដិបក្ខ ។ ប្រពន្ធ័ការពាររបស់អ្នក បង្កើតអង្គ បដិបក្ខនៅក្នុងខ្លួនទាំងនេះដើម្បីប្រឆាំង នឹងមេរោគ HIV ។

CD4 ឬកោសិកា T （ T Cells ）( ពេលខ្លះហៅថា កោសិកា T4(T-helper cells) ជួយដល់ប្រពន្ធ័ ការពារក្នុងខ្លួនរបស់អ្នកដើម្បីប្រឆាំងនឹងមេរោគ ។ នៅពេលដែលមេរោគ HIV បានជ្រាបចូលទៅក្នុងឈាម

1. វារុករកកោសិកា CD4 ហើយចាប់ផ្តើមបំបែកខ្លួនវាជាច្រើន ។
2. រំពេចនោះកោសិកាបំបែកពង្រាយវីរ៉ុសថ្មីនៅក្នុងឈាម ។ បន្ទាប់មកវីរ៉ុសដោយមិនមានទីបញ្ចប់ ។
3. កោសិកាផ្សេងៗទៀតនៃប្រពន្ធ័ការពារខ្លួន តបទៅវិញដោយរកកោសិកា ( បំផ្លាញ ចោល ។ ក្រោយមក CD4-Cell ដ៏ច្រើនត្រូវបានមេរោគបំផ្លាញរហូតធ្វើ ខ្លួនចុះខ្សោយគ្មានលទ្ធភាពទប់ទល់ នឹងជំងឺក្លាយនិងងជំងឺ ។




CD4 – T-cells

1. HIV វាចូលទៅក្នុងចរន្តឈាម 2&3 HIV ភ្ជាប់ខ្លួនវាទៅនឹងកោសិកា CD
4. HIV បញ្ចូលមេពូជរបស់វាទៅក្នុងកោសិកា CD4-T cell
5. ដំណើរពិសេសនេះធ្វើឱ្យមេពូជរបស់វាក្លាយទៅជាផ្នែកមួយនៃកោសិកា CD4-T cell ហើយចូលទៅក្នុងស្នូលនៃកោសិកានោះ ។
6. ឥឡូវនេះកោសិកា CD4-T cell ត្រូវបានឆ្លងមេរោគ HIV

7. មេរោគ HIV ចាប់ផ្តើម បង្កើនខ្លួនវាក្នុងកោសិកា CD4-T cell ដោយចម្លងខ្លួនវា ។

8. ទីបញ្ចប់កោសិកា CD4-T cell នោះត្រូវបំបែក ។  មេរោគ HIV ថ្មីរាប់ពាន់បានចេញទៅក្នុងប្រពន្ធ័ឈាម ។ មេរោគ HIV ថ្មីទាំងនេះធ្វើដំណើរ ទៅចម្លង កោសិកា ដទៃទៀត ។